# គំរូខ្សែច្រវាក់តម្លៃ
# គម្រោងពិពិធកម្មកសិកម្មកម្ពុជា




## ទីតាំងអ្នកទទួលផលគម្រោង




# ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# គម្រោងពិពិធកម្មកសិកម្មកម្ពុជា

IDA Credit No. 6366-KH


សម្រាប់ព័ត៌មានបន្ថែម៖

**ឯកឧត្តម ឃឹម ហ្វីណង់**

អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជានាយកគម្រោង

ទូរស័ព្ទ៖ ០១៧-៤០៨-៨៨៨ | អ៊ីម៉ែល៖ finankhim@maff.gov.kh

**លោក ណុប សុភឿន**

ប្រធានគ្រប់គ្រងគម្រោង CASDP

ទូរស័ព្ទ៖ ០១២-៦៤២-៧៦៧ | អ៊ីម៉ែល៖ sophoeun_nop@yahoo.com

**ធនាគារពិភពលោក**

**លោកស្រី ចំរើន មុទិតា** អ្នកឯកទេសអភិវឌ្ឍន៍ជនបទ ធនាគារពិភពលោក

អ៊ីម៉ែល៖ cmudita@worldbank.org

**លោកអ៊ិត ជំណាន**

អនុប្រធានទទួលបន្ទុករួម ការិយាល័យវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ទូរស័ព្ទ៖ ០១២-៤៤៥-៤៥៨ | អ៊ីម៉ែល៖ ith.chumnan@gmail.com


THE WORLD BANK
IBRD • IDA | WORLD BANK GROUP


ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
អាសយដ្ឋាន លេខ ២០០ មហាវិថីព្រះនរោត្តម ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
គេហទំព័រ៖ www.casdp.maff.gov.kh | Facebook: casdpcambodia


**កាលបរិច្ឆេទអនុម័តគម្រោង៖** ៣១ មករា ឆ្នាំ២០១៩

**កាលបរិច្ឆេទចុះកិច្ចព្រមព្រៀងផ្តល់ហិរញ្ញប្បទាន៖** ៣ មេសា ឆ្នាំ២០១៩

**កាលបរិច្ឆេទចាប់ផ្តើមអនុវត្ត៖** ០៥ មិថុនា ឆ្នាំ២០១៩

**កាលបរិច្ឆេទបញ្ចប់ការអនុវត្ត៖** ៣១ កក្កដា ឆ្នាំ២០២៦

**ហិរញ្ញប្បទាន៖**

ថវិកាសរុបចំនួន១០១,៦៧លានដុល្លារអាមេរិក៖

- ធនាគារពិភពលោក៖ ៩១,៦៧លានដុល្លារអាមេរិក
- ថវិកាបដិភាគពីរាជរដ្ឋាភិបាលកម្ពុជា៖ ១០លានដុល្លារអាមេរិក

**អ្នកទទួលផល និងលទ្ធផលរំពឹងទុក៖**

អ្នកទទួលផលផ្ទាល់របស់គម្រោងជាកសិករខ្នាតតូច និងមធ្យម ដែលកំពុងធ្វើអាជីវកម្មក្នុងសហគមន៍កសិកម្ម ឬក្រុមអ្នកផលិត ដែលមានសក្តានុពល និងមានចំណាប់អារម្មណ៍លើការអភិវឌ្ឍន៍កសិអាជីវកម្មរបស់ខ្លួន និងកសិករខ្នាតតូច និងមធ្យម ដែលចាប់អារម្មណ៍ក្នុងកិច្ចសហការផ្ទាល់ជាមួយកសិករ និងក្រុមអ្នកផលិត រួមគ្នាអភិវឌ្ឍខ្សែច្រវាក់អាជីវកម្ម/តម្លៃរបស់ពួកខ្លួន។

## អង្គភាពអនុវត្តគម្រោង

### អង្គភាពដឹកនាំអនុវត្តគម្រោង

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

### អង្គភាពអនុវត្តគម្រោង

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងធនធានទឹក និងឧតុនិយម ជាភ្នាក់ងារអនុវត្តគម្រោង។

ការអនុវត្តគម្រោងពិពិធកម្មកសិកម្ម ផ្អែកលើតម្រូវការអាទិភាពតាមរយៈផែនការសកម្មភាព និងថវិកា ស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា និងផែនការជាតិអភិវឌ្ឍន៍ដោយចីរភាព និងក្របខណ្ឌយុទ្ធសាស្ត្ររបស់ធនាគារពិភពលោក។

### ខេត្តគោលដៅអនុវត្តគម្រោង

ខេត្តបាត់ដំបង សៀមរាប ព្រះវិហារ ស្ទឹងត្រែង រតនគិរី ក្រចេះ មណ្ឌលគិរី ត្បូងឃ្មុំ កំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ កណ្ដាល ពោធិ៍សាត់ បន្ទាយមានជ័យ ឧត្តរមានជ័យ កំពង់ធំ តាកែវ និងរាជធានីភ្នំពេញ។



## ពិពិធកម្មកសិកម្ម

## ប្រព័ន្ធព័ត៌មានកសិកម្ម និងគ្រប់គ្រងការត្រួតពិនិត្យគុណភាព



## សាវតាគម្រោង

វិស័យកសិកម្មកម្ពុជាបានចូលរួមចំណែកដល់ផលិតផលសរុបក្នុងស្រុក (ផសស) ប្រមាណមួយភាគបួន និងផ្តល់ការងារធ្វើចំនួន ៣,១លាការងារនៅឆ្នាំ២០១៦។ ប្រជាជននៅតំបន់ជនបទប្រមាណ៤៦,៣% ស្មើនឹង៣លាននាក់នៅតែពឹងអាស្រ័យលើការងារកសិកម្ម។ ចាប់ពីឆ្នាំ២០១៣ វិស័យកសិកម្មមានការរីកលូតលាស់តិចតួច ដែលជាក្តីបារម្ភអំពីភាពខ្លាំង ការប្រកួតប្រជែង និងលទ្ធភាពបន្តជួយដល់ជីវភាពរស់នៅប្រកបដោយនិរន្តរភាពនៅពេលអនាគត។ កត្តាគំរាមកំហែងពីខាងក្រៅរួមមាន តម្លៃកសិផលធ្លាក់ចុះយ៉ាងគំហុក ភាពរាំងស្ងួត ទឹកជំនន់ បានធ្វើឲ្យវិស័យកសិកម្មមានការរីកលូតលាស់តិច។

អ្នកផលិតភាគច្រើន ជាពិសេសកសិករខ្នាតតូច និងមធ្យម ខ្វះចំណេះដឹង ជំនាញ ខ្វះធាតុចូលកសិកម្មដែលមានគុណភាព ខ្វះបច្ចេកទេសកែច្នៃកសិផលដើម្បីលក់នៅលើទីផ្សារ។ លើសពីនេះទៅទៀត កសិករខ្វះផ្លូវតភ្ជាប់ និងប្រព័ន្ធស្រោចស្រពដំណាំក្រៅពីស្រូវ ដែលធ្វើឲ្យការរីកលូតលាស់របស់វិស័យកសិកម្មនៅមានកម្រិត។

## គោលដៅគម្រោង

ធ្វើការសម្របសម្រួលខ្សែច្រវ៉ាក់តម្លៃពិពិធកម្មវិស័យកសិកម្មនៅក្នុងតំបន់ភូមិសាស្ត្រ ដែលនឹងត្រូវជ្រើសរើសនៅកម្ពុជា និងផ្តល់អន្តរាគមន៍ឆ្លើយតបជាបន្ទាន់ និងមានប្រសិទ្ធភាពក្នុងករណីមានវិបត្តិនិងសង្គ្រោះបន្ទាន់។

### ០១ សមាសភាគទី១៖ ជំរុញពិពិធកម្មកសិកម្ម

- គាំទ្រដល់ការរៀបចំ និងការអនុវត្តពិពិធកម្មខ្សែច្រវាក់តម្លៃកសិកម្ម ដោយមានការសម្របសម្រួលរវាងភាគីពាក់ព័ន្ធ ដែលមានបំណងធ្វើអាជីវកម្មរួមគ្នា គាំទ្រដល់ការរៀបចំ និងការវាយតម្លៃលើសំណើពិពិធកម្ម និងផែនការពិពិធកម្ម ចំពោះសំណើដែលបានជ្រើសរើស និងផ្តល់ការគាំទ្របច្ចេកទេសដល់ក្រុមអ្នកផលិត និងអាជីវកម្មកសិធុរកិច្ចខ្នាតតូច និងមធ្យម។
- ផ្តល់ហិរញ្ញប្បទានដល់ការធ្វើពិពិធកម្មកសិកម្ម ដោយបង្កើតឲ្យមានសេវាឥណទានបំពេញទុនវិនិយោគបន្ថែម ផ្គូរផ្គងដល់ក្រុមផលិត និងអាជីវកម្មកសិធុរកិច្ចខ្នាតតូច និងមធ្យមដើម្បីផ្សារភ្ជាប់ទៅនឹងខ្សែច្រវាក់តម្លៃ។

### ០២ សមាសភាគទី២៖ គាំទ្រហេដ្ឋារចនាសម្ព័ន្ធសាធារណៈ

- កែលម្អ ឬស្តារឡើងវិញប្រព័ន្ធស្រោចស្រព ដែលបញ្ជាក់នៅក្នុងផែនការពិពិធកម្ម។
- លើកកម្ពស់ការតភ្ជាប់ផ្លូវពីកសិដ្ឋានទៅកាន់ទីផ្សារ ដែលបញ្ជាក់នៅក្នុងផែនការពិពិធកម្ម។

## ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ



### ០៣ សមាសភាគទី៣៖លើកកម្ពស់ប្រព័ន្ធព័ត៌មានកសិកម្ម និងគ្រប់គ្រងការត្រួតពិនិត្យគុណភាព

- គាំទ្រដល់ការប្រមូល និងការផ្សព្វផ្សាយព័ត៌មានបច្ចេកទេស ព័ត៌មានទីផ្សារ ការវិភាគ និងការធ្វើផែនការគោលនយោបាយ។
- ពង្រឹងប្រសិទ្ធភាពនៃការការពារដំណាំ និងភូតគាមអនាម័យសុខភាពសត្វ និងការត្រួតពិនិត្យសុវត្ថិភាពស្បៀង ការធ្វើរបាយការណ៍ ប្រព័ន្ធអធិការកិច្ច និងប្រព័ន្ធជំរុញការអនុវត្តលិខិតបទដ្ឋាននៃធាតុចូលកសិកម្ម រួមមានការចេញវិញ្ញាបនប័ត្របញ្ជាក់ ការចេញច្បាប់អនុញ្ញាត សេវាគ្រប់គ្រង និងត្រួតពិនិត្យគុណភាពផ្សេងទៀត ការបង្កើត និងការអនុវត្តបទបញ្ញត្តិស្តីពីការអនុវត្តកសិកម្មល្អ និងផលិតផលសរីរាង្គ និងការអនុវត្តការចិញ្ចឹមសត្វល្អ និងការប្រើអត្តសញ្ញាណសំគាល់ភូមិសាស្ត្រ។

### ០៤ សមាសភាគទី៤៖ការគ្រប់គ្រង ការសម្របសម្រួល និងការតាមដាន និងវាយតម្លៃគម្រោង

- ផ្តល់មន្ត្រី និងទីប្រឹក្សាសំខាន់ៗក្នុងការសម្របសម្រួល និងអនុវត្តគម្រោង ដើម្បីជួយដល់អង្គភាពសម្របសម្រួលគម្រោងនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការគ្រប់គ្រងគម្រោង និងសហការជាមួយក្រុមការងារបច្ចេកទេសកសិកម្មទឹក និងគម្រោងផ្សេងៗទៀត។
- ជ្រើសរើសជំនួយការបច្ចេកទេស ដើម្បីគាំទ្រការអនុវត្តគម្រោង និងកសាងសមត្ថភាពមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអ្នកពាក់ព័ន្ធផ្សេងទៀត។

### ០៥ ការធ្វើអន្តរាគមន៍សម្រាប់ឆ្លើយតបសង្គ្រោះបន្ទាន់

ផ្តល់ការឆ្លើយតបជាបន្ទាន់ក្នុងករណីមានវិបត្តិ និងសង្គ្រោះបន្ទាន់នៅពេលមានការចាំបាច់។